**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ASIAN INFRASTRUCTURE INVESTMENT BANK

# ផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាននិងសង្គម
# នៃអនុគម្រោងស្តារជួសជុលសាងសង់ផ្លូវ នៃខ្សែផ្លូវកញ្ចប់ទី២
## (ខ្សែផ្លូវទឹកចេញ - អូរជូនតាក្រោម) ស្រុកសាលាក្រៅ ខេត្តប៉ៃលិន)

## សេចក្តីសង្ខេប


រាជរដ្ឋាភិបាលកម្ពុជា ទទួលបានកម្ចីពីធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដែលជាហិរញ្ញប្បទាន នៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ សម្រាប់កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីឆ្លើយតបទៅនឹងការរាលដាលជម្ងឺកូវីដ-១៩។ គម្រោងនេះអនុវត្តចាប់ពីខែកុម្ភៈឆ្នាំ២០២១ ដល់ខែមិថុនាឆ្នាំ២០២៤ ដែលមានក្រសួងអភិវឌ្ឍន៍ជនបទជាស្ថាប័នប្រត្តិបត្តិ ក្នុងខេត្តគោលដៅចំនួន៥ខេត្ត គឺខេត្តកំពង់ឆ្នាំង ព្រៃវែង ត្បូងឃ្មុំ ខេត្តកោះកុង និងខេត្តប៉ៃលិន។ គោលបំណងរបស់គម្រោងគឺដើម្បី ទ្រទ្រង់ដល់ជីវភាពនិងសេដ្ឋកិច្ចនៅជនបទ និងប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីការរាលដាលជម្ងឺកូវីដ-១៩ និងការបន្សាំនឹងស្ថានភាពបម្រែបម្រួលធាតុអាកាស។ គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ គឺតម្រូវអោយរៀបចំផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាន និងសង្គម។ លើសពីនេះ អ្នកទទួលការ ក៏ត្រូវរៀបចំផែនការសុវត្ថិភាពបរិស្ថាននិងសង្គម រួមបញ្ចូលទាំងផែនការសុខភាពនិងសុវត្ថិភាពការងារនិងយេនឌ័រ សម្រាប់អនុគម្រោងសាងសង់ផ្លូវជនបទ នៅតាមខេត្តគោលដៅ។

អនុគម្រោងខ្សែផ្លូវកញ្ចប់ទី២ (Lot 6: ខ្សែផ្លូវទឹកចេញ - អូរជូនតាក្រោម) ដែលស្ថិតនៅក្នុងឃុំបឹងស្ទឹងកាច់ និងឃុំអូរអណ្តូង ក្នុងស្រុកសាលាក្រៅ ខេត្តប៉ៃលិន មានប្រវែង២០,៨៥០ម៉ែត្រ ទទឹងប្រវែង៨ម៉ែត្រ បាននឹងកំពុងស្តារជួសជុលសាងសង់ឡើងវិញ ជាផ្លូវក្រាលកៅស៊ូពីរជាន់និងបេតុងសរសៃដែក។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវរួមមានសំណង់លូមូលចំនួន៤០កន្លែង ក្នុងនោះសំណង់លូមូលចំនួន២៥កន្លែងគឺត្រូវរក្សាទុកដូចដើម និង១៥កន្លែងត្រូវជួសជុលកសាងឡើងវិញ។ សំណង់លូមូល៣កន្លែងរក្សាទុកដូចដើម។ សំណង់លូប្រអប់ចំនួន៦កន្លែង ក្នុងនោះចំនួន៥កន្លែងរក្សាទុកដូចដើម។ អនុគម្រោងនេះបានចាប់ផ្តើមដំណើរការសាងសង់ពីខែឧសភា ឆ្នាំ២០២៣ រហូតដល់ខែមិថុនា ឆ្នាំ២០២៤ ដោយក្រុមហ៊ុន អ៊ឹងស៊ីមស៊ា ខនស្រ្តាក់សិន (Ung Simsia Construction Co., Ltd) ជាអ្នកទទួលការសាងសង់ ដែលត្រូវចំណាយថវិកាអស់ ៣,២៦៧,២២៦.០០ដុល្លាអាមេរិក។

ការសិក្សាវាយតម្លៃហេតុប៉ះពាល់នៃផែនការសុវត្ថិភាពបរិស្ថាននិងសង្គម គឺបានសិក្សានៅមុនពេលដំណើរការសាងសង់។ លទ្ធផលនៃការសិក្សាវាយតម្លៃបានបង្ហាញថា ប្រជាពលរដ្ឋដែលស្ថិតនៅសងខាងផ្លូវចំនួន១៥គ្រួសារ គឺទទួលរងផលប៉ះពាល់នៃការស្តារជួសជុលសាងសង់ផ្លូវនេះ។ ផលប៉ះពាល់បរិស្ថានដែលស្ថិតនៅសងខាងផ្លូវ រួមមានដើមឈើចំនួន២១ដើម និងការរំកិលតូបលក់ចាប់ហួយមួយចំនួន ដែលនៅលើដីចំណីផ្លូវ។ ទន្ទឹមនឹងនេះដែររដ្ឋបាលស្រុកសាលាក្រៅបានបញ្ជាក់ជាលាយល័ក្ខអក្សរ ធានាអះអាងពីការមិនប៉ះពាល់ដីធ្លីរបស់ប្រជាពលរដ្ឋ។ ការពិភាក្សា ជាសាធារណៈចំនួន២លើកបានរៀបចំឡើង។ ការពិភាក្សាជាសាធារណៈលើកទី១ បានធ្វើនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ ដែលមានប្រជាពលរដ្ឋចូលរួមចំនួន ១១៩នាក់ (ស្ត្រី៤១នាក់) និងការពិភាក្សាជាសាធារណៈលើកទី២ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ មានប្រជាពលរដ្ឋចូលរួមចំនួន ៩៧នាក់ ក្នុងនោះមានស្ត្រី៣០នាក់។

ចំពោះយន្តការបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានពីការត្អូញត្អែរផ្សេងៗ នៅក្នុងកំលុងពេលកំពុងសាងសង់គឺប្រជា-ពលរដ្ឋអាចផ្តល់ពត៌មានដែលពាក់ព័ន្ធនឹងការសាងសង់ផ្លូវ ដើម្បីបញ្ចៀសនូវការប៉ះពាល់ជាយថាហេតុណាមួយ។ យន្តការបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានពីការត្អូញត្អែរ គឺអាចធ្វើឡើង ដោយការជូនជាពត៌មានតាមទូរស័ព្ទឬសរសេរជាលាយល័ក្ខអក្សរផ្តល់ជូនទៅកាន់អាជ្ញាធរមូលដ្ឋាន (មេឃុំ ក្រុមប្រឹក្សាឃុំ ឬមេភូមិ) ឬអ្នកទទួលការសាងសង់ ឬក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទ ឬក៏ក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីចូលរួមដោះស្រាយ។ ចំពោះពត៌មានលម្អិតស្តីពីយន្តការបណ្តឹងតវ៉ា គឺមានបិទផ្សាយ និងរក្សាទុកនៅតាមសាលាឃុំ និងការដ្ឋានសាងសង់របស់អ្នកទទួលការ ដែលមានលេខទំនាក់ទំនងតាមគោលដៅនៃអនុគម្រោងនីមួយៗ។